00268445

ឯកសារ: D 97/3/2

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| **បញ្ជូនទៅ:** | សហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទនៃការបញ្ជូន** | ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន:** | **មេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ** |
| **ភាសាដើម:** | អង់គ្លេស និង ខ្មែរ (អត្ថបទបកប្រែ) |
| **ប្រភេទឯកសារ:** | សាធារណៈ |

**សារណារបស់អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហកម្មវត្ថុឧក្រិដ្ឋកម្មរួមអនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៨**

<u>បញ្ជូនដោយ៖</u>
**សហមេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**
លោកមេធាវី ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS Q

<u>អ្នកទទួលឯកសារ:</u>
**សហចៅក្រមស៊ើបអង្កេត**
លោក យូ ប៊ុនឡេង
លោក Marcel Lemond

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក ហុង គីមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី
លោក គង់ ពិសី
Silke Studzinsky
លោក យ៉ុង ផានីត
លោក គីម ម៉េងឃី
Martine JACQUIN

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 30 / 12 / 2008
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K.K. Ratanak

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K.K. Ratanak

# I. សេចក្តីផ្តើម

*កាលប្បវត្តិ*

1. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ មេធាវីការពាររបស់លោក អៀង សារី បានដាក់ "សំណើរបស់ខ្លួនប្រឆាំងនឹងការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា*សហកម្មឧក្រិដ្ឋកម្មរួម*[1](ហៅថា "**សំណើរបស់លោក អៀង សារី**") ដែលបានស្នើសុំឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "**ក.ស.ច.ស**") ប្រកាសថា សហកម្មឧក្រិដ្ឋកម្មរួម (ហៅកាត់ថា "JCE") មិនមែនជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបាននៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះទេ ។

2. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន ឆ្លើយតបទៅនឹងសំណើរបស់លោកអៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម(ហៅថា"**ចម្លើយតបរបស់ ក.ស.ព**")[2]។ នៅក្នុងចម្លើយតបរបស់ខ្លួន ការសន្និដ្ឋានជាបឋមរបស់សហព្រះរាជអាជ្ញា គឺថាសំណើរបស់លោក អៀង សារី មិនអាចទទួលយកបាន ហើយជម្រើសផ្សេងពីនេះ ត្រូវបដិសេធសំណើនេះដោយផ្អែកទៅតាមអង្គសេចក្តីរបស់វា ដោយសារតែ JCE អាចអនុវត្តបាននៅតុលាការនេះ ។

3. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ក.ស.ច.ស បានជូនដំណឹងទៅជនត្រូវចោទដទៃទៀតឱ្យបង្ហាញអំពីការកត់សំគាល់របស់ពួកគេទាក់ទងនឹងបញ្ហានេះនៅមុនថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០០៨[3] ដោយហេតុថា

> "បញ្ហាដែលបានលើកឡើង (...) វាមិនត្រឹមតែទាក់ទងនឹងលោក អៀង សារី តែប៉ុណ្ណោះទេ ប៉ុន្តែវាទាក់ទងនឹងជន ត្រូវចោទផ្សេងទៀត ហើយវាក៏ជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ អាស្រ័យហេតុនេះ វាជាការត្រឹមត្រូវក្នុងការអញ្ជើញភាគីទាំងអស់ឱ្យផ្តល់ការកត់សំគាល់ ដើម្បីឱ្យ [ក.ស.ច.ស] ធ្វើសេចក្តីសម្រេចដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់" ។

---

[1] សំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់ អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ឯកសារលេខ D97/2 ។

[3] ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨, ឯកសារលេខ D97/3 ។

4. ក្រុមការពាររបស់លោក អៀង សារី បានដាក់ការកត់សំគាល់បន្ថែមរបស់ខ្លួនស្តីពីការអនុវត្តនៅ អ.វ.ត.កនូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម(ហៅថា"**ការកត់សំគាល់បន្ថែមរបស់លោក អៀង សារី**")[4] នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ។ ស្របពេលជាមួយគ្នានេះដែរ អង្គបុរេជំនុំជម្រះបានធ្វើការដោះស្រាយលើបញ្ហា JCE នៅក្នុងករណីប្រឆាំងនឹង ឌុច ។នៅក្នុងសំណុំរឿងលេខ ០០១, ក.ស.ព បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ (ហៅថា "**បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ប្រឆាំងនឹងដីកាបញ្ជូនរឿង ឌុច**")[5]។ មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនពាក់ព័ន្ធជាមួយការខកខានរបស់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងមិនបានលើកឡើងថា JCE ជាទម្រង់នៃការទទួលខុសត្រូវមួយនោះទេ ។ ទាក់ទងនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះបានសម្រេចអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ផ្តល់ការណែនាំស្តីពីការអនុវត្ត JCE នៅ អ.វ.ត.ក[6]។ អ្នកដែលមិនមែនជាភាគីនៃរឿងក្តីចំនួនបីនាក់បានដាក់សារណារបស់ពួកគេកាលពីដំណាច់ខែតុលា ឆ្នាំ២០០៨ កន្លងទៅនេះ[7] ។ ជនត្រូវចោទ ឌុច ព្រមទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី[8] ។

---

[4] ការកត់សំគាល់បន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារលេខ D97/77 ។

[5] បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ប្រឆាំងនឹងដីកាបញ្ជូនរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ២០០៨, ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨, ឯកសារលេខ D99/3/3 (សំណុំរឿងលេខ ០០១) ។

[6] សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៨, ឯកសារលេខ D99/3/12, D99/3/13, និង D99/3/14 សំណុំរឿងលេខ ០០១) ។

[7] សារណារបស់លោកសាស្ត្រាចារ្យ Antonio Cassese និងសមាជិកនៃទស្សនាវដ្តីយុត្តធម៌ព្រហ្មទណ្ឌអន្តរជាតិ ស្តីពីទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨, ឯកសារលេខ D99/3/24 (ហៅថា "សារណារបស់សាស្ត្រាចារ្យ Antonio Cassese") (សំណុំរឿងលេខ ០០១), សារណារបស់មជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និង ពហុច្បាប់ (បច្ចុប្បន្នភាព) ឯកសារលេខ D99/3/25 (សំណុំរឿងលេខ ០០១), និង សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ប.ជ០២) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារលេខ D99/3/27 (សំណុំរឿងលេខ ០០១) (ហៅថា "សារណារបស់សាស្ត្រាចារ្យ **Kai Ambos**") ។

[8] ចម្លើយតបរបស់មេធាវីបរទេសរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ D99/3/32 (សំណុំរឿងលេខ ០០១), ចម្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ D99/3/33 (សំណុំរឿងលេខ ០០១), និង Réponse de la Défense aux Mémoires d'Amicus Curiae, ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ D99/3/37 (សំណុំរឿងលេខ ០០១) ។

00268448



5. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង កាំង ហ្គេចកអ៊ាវ ហៅ "ឌុច"[9] (ហៅថា "**សាលដីការបស់ អ.ប.ជ**") ជំទាស់នឹងការអនុវត្ត JCE នៅក្នុងសំណុំរឿងលេខ ០០១ ។

6. តាមរយៈនេះ ជនត្រូវចោទអ្នកស្រី អៀង ធិរិទ្ធ សូមដាក់សារណារបស់ខ្លួនប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម អនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ (ហៅថា "**សារណារបស់មេធាវីការពារ**") ។

## II. ច្បាប់នៅជាធរមាន

7. ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានកំណត់ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានក្នុងអំឡុងពេលវេលាពាក់ព័ន្ធចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។
មាត្រា ៨២ នៃក្រមនេះចែងថា:

"ជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្ម ឬ ទោសកម្មណាមួយ ដោយផ្ទាល់ក្តី, ដោយប្រយោលក្តី, ជននោះត្រូវមានទោសដូចជាអាទិចារី ។ ការចូលរួមប្រព្រឹត្តដោយផ្ទាល់នោះ ទុកជាសហចារី, រីឯការចូលរួមប្រព្រឹត្តដោយប្រយោល ទុកជាសមគំនិត"[10] ។

8. មាត្រា ៨៣ នៃក្រមដដែលចែងថា:

"ការចូលរួមប្រព្រឹត្តដោយប្រយោល ឬ ដោយសមគំនិត នឹងអាចមានទោសបាន កំលុះណាតែអំពើនោះបានសម្រេចមក ពីការនាំអាទិ៍, ការឲ្យអនុទ្ទេស, ការផ្តល់មធ្យោបាយ, ការជួយ ឬ ការទំនុកបំរុង"[11] ។

9. មាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា:

---

[9] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ឯកសារលេខ D99/3/37 (សំណុំរឿងលេខ ០០១) ។

[10] អត្ថបទបកប្រែក្រៅផ្លូវការ, សូមមើលសំណើរបស់លោក អៀង សារី អក្សរក្នុងលេខយោង លេខ៤១ ។

[11] អត្ថបទបកប្រែក្រៅផ្លូវការ, សូមមើលសំណើរបស់លោក អៀង សារី អក្សរក្នុងលេខយោង លេខ៤១ ។

"ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬ ជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ ។

10. មាត្រា ២ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា:

"ត្រូវបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធក្នុងតុលាការកម្ពុជាដែលមានស្រាប់ ពោលគឺសាលាដំបូង និង តុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ មករា ឆ្នាំ ១៩៧៩ ។

11. វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងអំពីសិទ្ធិរបស់ជនត្រូវចោទដែលត្រូវជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងលើខ្លួនគាត់ ដែលវិធាននេះបានចែងដូចខាងក្រោម:

"ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវបានចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន (...)" ។

12. ជាចុងក្រោយវិធាន ៥១(១) ចែងថា:

"ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការអង្កេត សហព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ដែលសង្ស័យថា បានចូលរួមក្នុងឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងឋានៈជាចារី ឬ អ្នកសមគំនិត ។ បុគ្គលនោះត្រូវតែប្រាប់ពីហេតុផលនៃការចាប់ខ្លួន និងសិទ្ធិទាំងឡាយរបស់បុគ្គលនោះ ដូចមានចែងក្នុងវិធាន ២១(១)(ឃ)" ។

## III. **អំណះអំណាង**

### ៣.១ **អំណះអំណាងសង្ខេប**

13. ជនត្រូវចោទយល់ស្របតាមអំណះអំណាងដែលមានចែងនៅក្នុងសំណើ និង ការកត់សំគាល់បន្ថែមរបស់លោក អៀង សារី ។ អំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាទាំងនោះបានបង្កើតជា ផ្នែកនៃសារណានេះ ។ តាមរយៈការសន្និដ្ឋានបឋម វាត្រូវបានអះអាងថា JCE មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលការនេះមិនត្រូវបានគេទទួលស្គាល់នោះទេ ។ ប្រសិនបើការអះអាងនេះមិនត្រឹមត្រូវ ហើយពេលនេះ JCE បែរជាត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូច្នេះវាក៏មិនអាចអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញបានដែរ ។

14. ជម្រើសផ្សេងពីនេះ ដូចដែលបានចែងនៅក្នុងសារណារបស់សាស្ត្រាចារ្យ Kai Ambos មេធាវីការពារសូមជូនសំអាងថា មានតែ JCE ទម្រង់ទីមួយ ឬ ទម្រង់មូលដ្ឋានទេ អាចអនុវត្តបាន អាស្រ័យហេតុនេះ សូមច្រានចោល JCE ទម្រង់ទីពីរ និងទីបី ចេញពីយុត្តាធិការរបស់ អ.វ.ត.ក ។ មេធាវីការពារនឹងពន្យល់លំអិតអំណះអំណាងទូទៅនេះ នៅក្នុងរយៈពេលនៃការដាក់សារណាទាំងនេះ ។

## ៣.២ លក្ខខណ្ឌតម្រូវចំពោះការអនុវត្ត JCE

15. សហព្រះរាជអាជ្ញាលើកឡើងថា ដើម្បីអនុវត្តនៅចំពោះមុខ អ.វ.ត.ក បាន នោះទម្រង់នៃការទទួលខុសត្រូវចំពោះ JCE ត្រូវបំពេញលក្ខខណ្ឌចំនួនបួន: (i) ទម្រង់ JCE នេះត្រូវមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទោះជាច្បាស់លាស់ ឬមិនច្បាស់លាស់ក៏ដោយ (ii) ទម្រង់ JCE នេះត្រូវមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ (iii) ច្បាប់ដែលចែងពីទម្រង់ JCE នេះត្រូវផ្តល់លទ្ធភាពគ្រប់គ្រាន់ដើម្បីឲ្យចុងចោទទទួលបាននៅក្នុងពេលវេលាពាក់ព័ន្ធ និង(iv)ចុងចោទត្រូវព្យាករណ៍ដឹងជាមុនថា ខ្លួនអាចទទួលខុសត្រូវពីបទព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន[12]។ ប៉ុន្តែសារណារបស់សាស្ត្រាចារ្យ Kai Ambos ដែលមិនមែនជាភាគីនៃរឿងក្តីបានលើកឡើងពីលក្ខខណ្ឌតម្រូវផ្សេង និងមានលក្ខណៈទូលំទូលាយជាង ដែលសារណានោះបានឆ្លុះបញ្ចាំងពីលក្ខខណ្ឌផ្លូវច្បាប់នៃការទទួលខុសត្រូវលើ JCE ច្បាស់លាស់ជាង និងបានសំអាងទៅលើសាលដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនៅក្នុងរឿងក្តីប្រឆាំងនឹង Milutinovic[13]។ សាស្ត្រាចារ្យ Kai Ambos លើកឡើងពីលក្ខខណ្ឌតម្រូវដូចខាងក្រោម:

(i) JCE ត្រូវមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលវេលាពាក់ព័ន្ធ

---

[12] សូមមើលចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៨ ។

[13] សារណារបស់សាស្ត្រាចារ្យ Kai Ambos ដែលជាអ្នកមិនមែនជាភាគីនៃរឿងក្តី ទំព័រ ២១ ។

(ii) JCE ត្រូវបង្កើតបានជាផ្នែកនៃច្បាប់កម្ពុជានៅក្នុងពេលវេលាពាក់ព័ន្ធ

(iii) ចុងចោទត្រូវមានលទ្ធភាពគ្រប់គ្រាន់ និងព្យាករណ៍ដឹងជាមុនពីទម្រង់នៃ JCE នេះ នៅក្នុងពេលវេលាពាក់ព័ន្ធ និង

(iv) បន្ថែមទៅលើចំនុចលើកឡើងខាងលើ ច្បាប់ដែលអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ត្រូវចែងពីទម្រង់នៃការទទួលខុសត្រូវបែបនេះ។

16 ចម្លើយតបរបស់ ក.ស.ព មិនបានបញ្ចូលការទាមទារទីពីរដែលបានលើកឡើងដោយសាស្ត្រាចារ្យ Ambos ពីការជំទាស់តវ៉ារបស់ខ្លួននោះទេ គឺភាពចាំបាច់ដែលថា JCE បង្កើតបាន ជាផ្នែក មួយនៃច្បាប់កម្ពុជាចំពោះពេលវេលាពាក់ព័ន្ធ ដែលសាស្ត្រាចារ្យ Kai Ambos បានលើកឡើងថា ជាការចាំបាច់ក្នុងការសម្រេចពីបញ្ហាជាមូលដ្ឋាននេះ ។

17 សាស្ត្រាចារ្យ Kai Ambos ធ្វើសេចក្តីសន្និដ្ឋានថា មានតែ JCE ទម្រង់ទីមួយប៉ុណ្ណោះដែលជាផ្នែកមួយយ៉ាងច្បាស់លាស់នៃច្បាប់កម្ពុជា នៅពេលវេលាដែលពាក់ព័ន្ធ។ ការអនុវត្ត JCE ទម្រង់ទីពីរ គឺមានភាពមិនច្បាស់លាស់ និងមិនប្រាកដប្រជា និងហេតុដូច្នេះ មិនគួរត្រូវបានយកមកសំអាងដល់ការធ្វើឲ្យខូចប្រយោជន៍របស់ជនត្រូវចោទនោះទេ ហើយ JCE ទម្រង់លាតសន្ធឹងមិនបានបង្កើតទៅជាផ្នែកមួយនៃច្បាប់កម្ពុជានៅពេលដែលពាក់ព័ន្ធនោះទេ[14]។

## ៣.៣ JCE មិនត្រូវបានគេសំអាងឲ្យបានត្រឹមត្រូវទេ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

18 នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះយល់ឃើញថា “ការបង្កើតសហកម្មឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងកថាខណ្ឌទី ៧២ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ មានលក្ខណៈស្រពិចស្រពិល ជាពិសេស ដោយសារវាពាក់ព័ន្ធនឹងការថ្លែងសំអាងចំពោះទម្រង់ខុសៗគ្នាទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម”[15]។ អង្គបុរេជំនុំជម្រះបានបន្ត ថា:

[14] សារណារបស់សាស្ត្រាចារ្យ Kai Ambos ដែលជាអ្នកមិនមែនជាភាគីនៃរឿងក្តី ទំព័រ ៣០ ។

[15] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៣៥ ។

"ការបញ្ជាក់ឱ្យបានច្បាស់លាស់ គឺជាការចាំបាច់ ដើម្បីធ្វើការញែកទស្សនៈទាននៃសហកម្មឧក្រិដ្ឋកម្មរួម ពីទម្រង់នៃការទទួលខុសត្រូវផ្សេងៗដែលអាចប្រៀបធៀបគ្នាបាន ហើយដែលអាចនៅជាធរមាន អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា"។

19 មេធាវីការពារសូមលើកឡើងថា JCE ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿងលេខ០០២ ហាក់មានភាពស្រពិចស្រពិល និងមិនច្បាស់លាស់។ ទម្រង់ផ្សេងៗគ្នានៃ JCE ដែលបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណី ឌុច មានលក្ខណៈពិសេស និងច្បាស់លាស់ជាង JCE ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿងលេខ០០២។ សេចក្តីលំអិតនៃទម្រង់ JCE ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវបានបកស្រាយលំអិតដូចខាងក្រោម។

20. ខណៈដែល ក.ស.ព ហាក់ដូចជាសំអាងទៅលើ JCE ទម្រង់ទីពីរ នៅក្នុងកថាខណ្ឌ ៥ ដល់ ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះកថាខណ្ឌ ១១៦ ហាក់ដូចជាសំអាងទៅលើ JCE ទម្រង់ទីមួយ ឬទីបីទៅវិញ។ កថាខណ្ឌពាក់ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងដូចខាងក្រោមនេះ៖

៥. ផែនការឧក្រិដ្ឋកម្មរួម ឬ សហកម្មឧក្រិដ្ឋកម្មរួម ចាប់ផ្តើមនៅថ្ងៃ ឬមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ហើយបានបន្តអត្ថិភាពយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។

៦. កម្មវត្ថុនៃផែនការឧក្រិដ្ឋកម្មរួមនេះ គឺការធ្វើទុក្ខបុកម្នេញដែលមានលក្ខណៈជាប្រព័ន្ធមកលើក្រុម ជាក់លាក់មួយចំនួន នៅក្នុងចំណោមប្រជាជនកម្ពុជា ដោយយកលេសថាដើម្បីបង្កើតនូវសង្គមមួយដែលជាសង្គមមានសមាសភាគកម្មជាតិពន្ធុ គ្មានសាសនា និង គ្មានវណ្ណៈ ដោយលុបបំបាត់ ចោលនូវភាពផ្សេងៗគ្នាផ្នែក វប្បធម៌ វណ្ណៈ ពូជសាសន៍ សាសនា ជនជាតិ និងជាតិពន្ធុទាំងអស់ តាមរយៈការប្រព្រឹត្តបទល្មើសដែល អាចផ្តន្ទាទោសបានតាមមាត្រាទី ៣ ថ្មី ៤, ៥, ៦ និង ៧ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អ្វីក៏ដោយ ឬជនណាក៏ដោយ ដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថាជាការគំរាមកំហែង ឬជាឧបសគ្គដល់គោលនយោបាយ និង មនោគមន៍វិជ្ជារបស់ខ្លួន និងត្រូវបានសម្លាប់ និងបំផ្លាញចោល រួមទាំងភាពផ្សេងៗគ្នានៃជាតិពន្ធុ និង សាសនាទាំងអស់ រួមទាំងវណ្ណៈសក្តិភូមិ វណ្ណៈមូលធន និងវណ្ណៈគហបតី និងជនទាំងអស់ដែល

គេយល់ថាជាជនក្បត់ នៅក្នុងចំណោមប្រជាជន ឬនៅក្នុងចំណោមកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។

៧. កម្មវត្ថុនៃផែនការឧក្រិដ្ឋកម្មរួមនេះ ក៏រួមបញ្ចូលទាំងការបដិសេធនូវសិទ្ធិជាមូលដ្ឋានដូចជា សិទ្ធិមានសេរីភាព សន្តិសុខបុគ្គល និងទ្រព្យសម្បត្តិ សិទ្ធិសេរីភាពក្នុងការ បញ្ចេញមតិ យោបល់ គំនិត សតិសម្បជញ្ញៈ និងសាសនា និងសិទ្ធិមានគ្រួសារ និង ជីវិត ផ្ទាល់ខ្លួន ដល់សមាជិកនៃប្រជាជនដែលមិនត្រូវបានកំណត់អត្តសញ្ញាណថា ជាសមាជិកក្នុងគោលដៅទាំងនេះទេ។

៨. បុគ្គលដែលបានចូលរួមដោយបានដឹង និងដោយស្ម័គ្រចិត្ត នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមពេញរយៈ ពេលរបស់វា ឬផ្លាស់គ្នាតាមពេលនៃរយៈពេលនោះ នៅក្នុងពេលផ្សេងគ្នាណាមួយនៃអំឡុងពេល វេលានោះ រួមមាន តែមិនកំណត់ត្រឹមតែ: **នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ** និង **កាំង ហ្កេចអ៊ាវ (ឌុច)** (...)។ បុគ្គលទាំងអស់នេះបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមជា សហចារី ដោយផ្ទាល់ ឬដោយប្រយោល។ ពួកគេគិតទុកជាមុនថា នឹងមានឧក្រិដ្ឋកម្មកើតឡើង ទោះបីជាពួកគេមិនបានប្រព្រឹត្តដោយខ្លួនឯងផ្ទាល់ នូវបទល្មើសទាំងអស់ ដូចមានរៀបរាប់នៅក្នុង កថាខណ្ឌ ៣៧ ដល់ ៧២ ក៏ដោយ។

៩. ជនសង្ស័យបានដឹងពីផែនការ ដែលមានលក្ខណៈជាប្រព័ន្ធធ្វើទុកបុកម្នេញ និង ប្រព្រឹត្តកម្មយង់ឃ្នង មកលើប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចបានឆ្លុះបញ្ចាំងតាមរយៈការបង្កើតនូវមន្ទីរសន្តិសុខ ជំរុំធ្វើការដោយបង្ខំ មណ្ឌលលត់ដំ និងសហករណ៍នានាជាច្រើន នៅទូទាំងកម្ពុជាប្រជាធិបតេ្យ ដែលមានលក្ខណៈជាប្រព័ន្ធ។ ជនសង្ស័យបានដឹងពីសភាពនៃប្រព័ន្ធនៃការបង្ក្រាប បានចូលរួមក្នុងការប្រតិបត្តិ ព្រមទាំងមានផែនការមានលក្ខណៈជាប្រព័ន្ធបន្ថែមទៀត សម្រាប់ការ ធ្វើទុក្ខបុកម្នេញ និងការធ្វើបាប។ ដូច្នេះហើយ ដោយបានដឹង និងស្ម័គ្រចិត្ត បានចូលរួមជ្រោមជ្រែងឲ្យជឿនលឿនទៅមុខនូវគោលបំណងរួមនៃសហកម្មឧក្រិដ្ឋរួមនេះ។

១០. ជនសង្ស័យម្នាក់ៗ ដោយធ្វើសកម្មភាពជាបុគ្គល ឬដោយរួមជាមួយសហចារីដែលមាន និង មិនមាន ឈ្មោះ បានចូលរួមដល់សហកម្មឧក្រិដ្ឋកម្មរួម ដោយប្រើសិទ្ធិអំណាចជាក់ស្តែង និងស្របច្បាប់ របស់ពួកគេ (*de jure* and *de facto authority*)។ ជនសង្ស័យបានដឹងនិងបានអនុវត្តការត្រួតត្រា ដោយមានប្រសិទ្ធភាពលើបទល្មើសទាំងនោះ ដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ពួកគេ ពីព្រោះដោយសារតែមានបណ្តាញបញ្ជា

ការឃោសា និងស៊ីវិល ដែលមាន ទើបគេរាយការណ៍ទៅថ្នាក់លើបំផុតនៃរដ្ឋបាល និង សម្រាប់តាមដានការងារនៅរដ្ឋបាលថ្នាក់ក្រោមទាំងអស់។

១៦.**នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ** និង **ឌុច** បានប្រព្រឹត្តបទឧក្រិដ្ឋ ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ ដោយបានសម្របសម្រួល និង ចូលរួមក្នុង សហកម្មឧក្រិដ្ឋកម្មរួម តាមវិធីដូចបានបង្ហាញ។ សកម្មភាពរបស់ពួកគេបានបណ្ដាល ឲ្យប្រជាជនស្លាប់ចំនួនពី ១ លាន ៧ សែននាក់ ដល់ ២ លាន ២ សែននាក់ ពីក្នុងចំណោម ប្រជាជនប្រហែល ៧ លាននាក់ ដោយសារតែការធ្វើឲ្យបាក់កម្លាំង ភាពអត់ឃ្លាន ជម្ងឺ ឬ ការប្រហារជីវិត។ ទោះបីជាអ្នកដែលមិន ត្រូវបានសម្លាប់ក្ដី ក៏ជាជនរងគ្រោះនៃគោល នយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ហើយពួកគេទទួលរងការធ្វើទារុណកម្ម ការធ្វើការដោយបង្ខំ ការឃុំខ្លួនដោយខុសច្បាប់ ការធ្វើទុកបុកម្នេញផ្នែកសាសនា ការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំ និងប្រព្រឹត្តកម្មអមនុស្សធម៌ដទៃទៀត។

១១៦.ជនសង្ស័យទាំងនេះបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលពួកគេបានចូលរួមក្នុងសហកម្មឧក្រិដ្ឋ កម្មរួម ជាមួយសហចារីដទៃទៀត។ ឧក្រិដ្ឋកម្មទាំងអស់នេះ គឺជាកម្មវត្ថុនៃសហកម្ម ឧក្រិដ្ឋកម្មរួម ឬក៏អាចជាបច្ច័យដែលមានលក្ខណៈធម្មជាតិ និងអាចគិតទុកជាមុនបាន។ ជនសង្ស័យបានដឹង ឬគួរតែបានដឹងថា ឧក្រិដ្ឋកម្មបែបនេះមានបច្ច័យដែលមានលក្ខណៈ ធម្មជាតិ និងដែលអាចគិតទុកជាមុនបាន ក្នុងការប្រតិបត្តិរបស់សហកម្មឧក្រិដ្ឋកម្មរួម និងបានសម្រេចចូលរួមនៅក្នុងការប្រព្រឹត្តនោះ។ សមាជិកដទៃទៀតរបស់សហកម្មឧក្រិដ្ឋកម្មរួមនេះបានធ្វើសកម្មភាពដោយឈរលើមូលដ្ឋាននៃកម្មវត្ថុរួមគ្នានេះ ដោយមាន ចេតនារួមគ្នា។

21. ខណៈដែលកថាខណ្ឌទី ៥ ដល់ទី ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរយោងទៅលើ JCE ទម្រង់ទីពីរ តែប៉ុណ្ណោះ ហើយ កថាខណ្ឌទី ១១៦ ដែលស្ថិតនៅផ្នែកសន្និដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូន រឿងឲ្យស៊ើបសួរ សហព្រះរាជអាជ្ញាបានផ្អែកទៅលើ JCE ទម្រង់ទីមួយ និងទីបី ដោយមិនបានធ្វើ សេចក្ដីយោងណាមួយទៅនឹងភស្តុតាងជាក់លាក់ដែលគាំទ្រដល់ JCE ទម្រង់ទាំងពីរនេះឡើយ។

22. ការដែលថា JCE ទម្រង់ទីមួយ និង ទីបី ដែលត្រូវបានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ ហើយពុំមានភស្តុតាងជាមូលដ្ឋាននៅក្នុងឯកសារ ចោទប្រកាន់ ដើម្បីគាំទ្រដល់ការអះអាងដែលថា ទម្រង់ JCE ទាំងនោះត្រូវបានសំអាងគ្រប់គ្រាន់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ វាពុំមានភាពច្បាស់លាស់ដែលតម្រូវដោយអង្គ បុរេជំនុំជម្រះនោះទេ ។

23. យើងសូមលើកឡើងថា ចម្លើយតបរបស់សហព្រះរាជអាជ្ញាមិនបានកំណត់គ្រប់គ្រាន់អំពី JCE ហើយខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់អង្គបុរេជំនុំជម្រះនោះទេ ។ ដូច្នេះវាពិតជាបានរំលោភបំពានលើសិទ្ធិប្រាប់អំពីការចោទប្រកាន់ប្រឆាំងនឹងខ្លួនរបស់ជនត្រូវចោទ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១(១)(ឃ) ។

## ៣.៤ ច្បាប់កម្ពុជាជំនួសឱ្យច្បាប់អន្តរជាតិដែលមិនច្បាស់លាស់

24. លោកសាស្ត្រាចារ្យ Kai Ambos បានសន្និដ្ឋាននៅក្នុងសារណារបស់គាត់ថា "មានតែ JCE I ប៉ុណ្ណោះដែលមានន័យច្បាស់លាស់ ខណៈដែល JCE III មិនត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ ចំពោះ JCE II វិញ វាអាស្រ័យតែទៅលើការបកស្រាយថាជាប្រភេទនៃ JCE I ឬក៏ជាការពន្លាតនៃការទទួលខុសត្រូវនៅក្នុងអត្ថន័យនៃ JCE III តែប៉ុណ្ណោះ"[16]

25. តាមការបង្ហាញនៅក្នុងសារណាររបស់ Kai Ambos គឺថា មានភាពមិនច្បាស់លាស់ចំពោះ JCE ទម្រង់ទីពីរ ដែលត្រូវកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជានៅក្នុងអំឡុងពេលពាក់ព័ន្ធ ។ លោក Ambos បានសន្និដ្ឋានថា JCE ទម្រង់ទីបី មិនបានបង្កើតជាផ្នែកមួយនៃច្បាប់កម្ពុជាក្នុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ ខណៈដែលគាត់យល់ឃើញថា JCE ទម្រង់ទីមួយអាចអនុវត្តបាននាពេលនោះ ។

26. ជាផលវិបាក និងដោយពិចារណាលើគោលការណ៍ដែលថា "ចៅក្រមតម្រូវឱ្យបកស្រាយច្បាប់ព្រហ្មទណ្ឌឱ្យបានហ្មត់ចត់ដោយផ្តល់ផលប្រយោជន៍ដល់ជនត្រូវចោទក្នុងករណីមានវិមតិសង្ស័យ"[17] ប្រសិនបើអំណះអំណាងបឋមរបស់មេធាវីការពារក្តីមិនបានជោគជ័យទេ គឺមានតែ JCE ទម្រង់ទីមួយប៉ុណ្ណោះ ដែលជាទម្រង់មូលដ្ឋាន ត្រូវអនុវត្តនៅ អ.វ.ត.ក ដោយប្រានចោល JCE ទម្រង់ទីពីរ និង ទីបី ។

27. បន្ថែមពីលើនេះ មេធាវីការពារក្តីសូមលើកឡើងថា ការអនុវត្ត និងការបកស្រាយ JCE គឺពិតជាត្រូវបានជំទាស់ដ៏ទូលំទូលាយ ហើយនិងធាតុផ្សំពិតប្រាកដរបស់វា ប្រសិនជាត្រូវអនុវត្តនោះមែននោះនឹងត្រូវបើកឱ្យមានការបកស្រាយផ្ទុយគ្នា និងខុសៗគ្នាជាមិនខាន ដូចមានភស្តុតាងដែលបានលើកឡើងនៅក្នុងការពិភាក្សាអំពីការអនុវត្តនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១ ។ ក្រមព្រហ្ម

---

[16] សារណាមិនមែនភាគីរបស់ Kai Ambos, ទំព័រ.៣០

[17] សារណាមិនមែនភាគីរបស់ Kai Ambos, ទំព័រ.២០

ទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានចែងអំពីទម្រង់ពីរខុសពីគ្នាគឺ សហចារី និងអ្នកសមគំនិត ដែលដូចគ្នាច្រើនជាសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ជាមូលដ្ឋាន និងទម្រង់ទីពីររបស់វា ។ ជាដំបូង អ.វ.ត.ក គួរតែអនុវត្តនូវច្បាប់កម្ពុជាជាមុនសិន ហើយត្រូវផ្អែកលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចៀសជាងយកទម្រង់នៃការទទួលខុសត្រូវមួយដ៏ចំរូងចំរាស់នៅក្រោមច្បាប់អន្តរជាតិ ។

## ៣.៥ សេចក្តីសន្និដ្ឋាន

28. ជាបឋម និង ដោយយល់ស្របជាមួយអំណះអំណាងដែលបានលើកឡើងនៅក្នុងសំណើ និងការកត់សំគាល់បន្ថែមរបស់លោក អៀង សារី មេធាវីការពារសូមលើកឡើងថា ទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា JCE មិនអាចអនុវត្តបានចំពោះនីតិវិធីនៃ អ.វ.ត.ក បានទេ ដោសារតែទម្រង់នៃការទទួលខុសត្រូវនេះ មិនអាចអនុវត្តនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជានាពេលវេលាដែលពាក់ព័ន្ធនេះទេ ។

29. ទីពីរ និងជាថ្មីម្តងទៀត មេធាវីការពារក្តីសូមលើកឡើងថា តម្រូវការនៃការអនុវត្ត JCE ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា គឺមិនគ្រប់គ្រាន់នោះទេ។ តាមការលើកឡើងរបស់លោក Kai Ambos មានតែ JCE ទម្រង់ទីមួយ ប៉ុណ្ណោះ ដែលពិតជាត្រូវអាចអនុវត្តបាននៅក្នុងច្បាប់កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធ ។ ដោយហេតុនេះ ទម្រង់ទីពីរ និងទីបី គឺមិនអាចអនុវត្តនៅ អ.វ.ត.ក បានទេ ។

30. ទីបី ចំពោះសេចក្តីយោងជាក់លាក់ទៅនឹងទម្រង់ទីមួយ និងទីពីរនៃ JCE ទាំងអស់នេះវាមិនគ្រប់គ្រាន់ទាល់តែសោះចំពោះការអះអាងដែលលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលជាលទ្ធផលគឺសហព្រះរាជអាជ្ញាបានរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់ ។

31. ដោយហេតុថា វិធាន ២១(១)(ឃ) ដែលត្រូវយកមកអនុវត្តចាប់ពីពេលវេលានៃការចាប់ខ្លួនតទៅ[18] ការខកខានបែបនេះពិតជាមិនអាចកែបានឡើយ ហើយដែលនាំឲ្យមានការមិនរាប់បញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ វិធានផ្ទៃក្នុង ៥១(១) បានចែងថា:

[18] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌទី១៤០

"ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការអង្កេត សហព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ដែលសង្ស័យថាបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងឋានៈជាចារី ឬ អ្នកសមគំនិត។ បុគ្គលនោះត្រូវតែបានប្រាប់ពីហេតុផលនៃការឃាត់ខ្លួន និងសិទ្ធិទាំងឡាយរបស់បុគ្គលនោះដូចមានចែងក្នុងវិធាន ២១ (១)(ឃ)"។

## IV. សំណូមពរ

32. សំរាប់ហេតុផលទាំងអស់នេះ ជនត្រូវចោទសូមស្នើដោយក្តីគោរពថា:

(i) ជាបឋម ការិយាល័យសហចៅក្រមស៊ើបអង្កេតគួរតែប្រកាសថា អ.វ.ត.ក មិនមានយុត្តាធិការទៅលើ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមួយទេ ។

(ii) ផ្ទុយទៅវិញ អ.វ.ត.ក មានយុត្តាធិការដើម្បីអនុវត្តតែទៅលើ JCE ទម្រង់ទីមួយប៉ុណ្ណោះ ហើយដែលទម្រង់ទីពីរ និងទីបី គឺមិនត្រូវបានគេទទួលស្គាល់ឡើយ ហើយត្រូវបដិសេធចោល ។

(iii) លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាមិនបានលើកឡើងឱ្យបានគ្រប់គ្រាន់នូវ JCE ទម្រង់ទីមួយ និងទីបីនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយជាលទ្ធផល JCE គ្រប់ទម្រង់ទាំងអស់មិនអាចអនុវត្តបាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ:០០២ បានឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨

សហមេធាវី អ្នកស្រី អៀង ធិរិទ្ធ
លោក ផាត់ ពៅសឺង
Ms. Diana ELLIS, QC